# ប្រកាសព័ត៌មាន លេខ ៤២ (ខែ កញ្ញា ឆ្នាំ ២០១៧)




សម្រាប់ខែកញ្ញានេះ លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចូលរួមធ្វើបទបង្ហាញ ផ្សព្វផ្សាយអំពីសមិទ្ធផលគន្លឹះ និងផ្តល់បទពិសោធន៍ ជុំវិញប្រធានបទ “ *ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*” ក្នុងគោលបំណងដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍ជាមួយបណ្តាប្រទេសផ្សេងៗដែលធ្លាប់បានអនុវត្តច្រើនឆ្នាំ លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ។

ក្រៅពីនេះលេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS ក៏បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងនៃក្រុមការងារ FMWG ដើម្បីដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនទាក់ទង ការត្រៀមលក្ខណៈក្នុងការដាក់ប្រព័ន្ធ FMIS ឱ្យអនុវត្តនៅតាមក្រសួង-ស្ថាប័នទាំង ១០ សម្រាប់ឆ្នាំគ្រប់គ្រងហិរញ្ញវត្ថុ ២០១៨ ខាងមុខនេះ ។ ក្នុងកិច្ចប្រជុំនេះផងដែរ ក្រុមការងារក៏បានធ្វើបទបង្ហាញអំពីលក្ខណៈថ្មីរបស់ប្រព័ន្ធដែលហៅថា ពហុអង្គភាពការងារ (Multiple Business Units) ដល់ក្រុមការងារទាំងអស់ឱ្យយល់ច្បាស់អំពីលក្ខណៈពិសេសមួយនេះ ដែលអាចធ្វើឱ្យប្រព័ន្ធ FMIS កាន់តែមានភាពងាយស្រួល និង មានសុវត្ថិភាពជាងមុន ។

ស្របពេលជាមួយគ្នានេះ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងការប្រើប្រាស់ប្រព័ន្ធ FMIS ឱ្យបានជោគជ័យប្រកបដោយប្រសិទ្ធិភាព ក្រុមកាងារផ្នែកកសាងសមត្ថភាព បានជួបប្រជុំជាមួយក្រុមការងារពាក់ព័ន្ធទាំងអស់ក្នុងការកំណត់នូវមាតិកាមេរៀន គ្រូបង្គោល និង កំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ប្រព័ន្ធ FMIS នៅតាមក្រសួង-ស្ថាប័ន ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់ប្រព័ន្ធ FMIS ឱ្យមានភាពរលូន និង សម្រេចបានទៅតាមកាលវិភាគដែលបានកំណត់ដូចខាងក្រោម÷




*កាលវិភាគវគ្គបណ្តុះបណ្តាលអ្នកប្រើប្រាស់ប្រព័ន្ធ FMIS នៅក្រសួង-ស្ថាប័ន*

## ផ្នែកគ្រប់គ្រងការផ្លាស់ប្តូរ

ក្រុមការងារគ្រប់គ្រងការផ្លាស់ប្តូរ បានបន្តធ្វើបច្ចុប្បន្នភាពជាប្រចាំទៅលើគេហទំព័រ បណ្តាញសង្គម និងបានផ្សព្វផ្សាយនូវ ផ្ទាំងព័ត៌មាន (Posters) នានា និង ផលិតជាវីដេអូដើម្បីផ្សព្វផ្សាយទៅដល់ភាគីពាក់ព័ន្ធ និង សាធារណជន ឱ្យបានយល់ដឹងពីសកម្មភាពនៃការអនុវត្ត និង វឌ្ឍនភាពនៃការអនុវត្តគម្រោង FMIS ។




## ផ្នែកហេដ្ឋារចនាសម្ព័ន្ធ

រីឯក្រុមការងារផ្នែកគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបានសិក្សា និងពិភាក្សាជាមួយក្រុមការងារបច្ចេកទេស ក្នុងការធ្វើសន្ធានកម្មប្រព័ន្ធ FMIS ជាមួយធនាគារថ្មីមួយទៀត គឺ ធនាគារកម្ពុជាសាធារណៈ និង បានបន្តដោះស្រាយបញ្ហានានា ពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន សម្រាប់អ្នកប្រើប្រាស់ នៅក្នុងកំឡុងពេលប្រើប្រាស់ប្រព័ន្ធ FMIS ។



## ផ្នែកមុខងារប្រព័ន្ធ

សម្រាប់ក្រុមការងារផ្នែកមុខងារប្រព័ន្ធវិញ បានធ្វើការសម្អាតទិន្នន័យ និង ប្រតិបត្តិការដែលមិនប្រើប្រាស់នៅឆ្នាំ២០១៦ ដល់អ្នកប្រើប្រាស់ប្រព័ន្ធ FMIS ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។ ហើយក្រុមការងារក៏បន្តសម្របសម្រួល និង ដោះស្រាយបញ្ហាផ្សេងៗជាច្រើន ជាពិសេសបញ្ហា និងសំណើដែលលើកឡើងនៅក្នុងប្រព័ន្ធ Helpdesk ក្នុងកំឡុងពេលប្រើប្រាស់ប្រព័ន្ធ FMIS ជាមួយអគ្គនាយកដ្ឋានគន្លឹះៗ និង រតនាគាររាជធានី-ខេត្តទាំង ២៥។




*ក្រុមការងារកំពុងរៀបចំវគ្គបណ្តុះបណ្តាលពីការប្រើប្រាស់កុំព្យូទ័រ មុខងារប្រព័ន្ធ FMIS និងវគ្គបណ្តុះបណ្តាលមូលដ្ឋានផ្សេងៗទៀតដល់អ្នកប្រើប្រាស់ប្រព័ន្ធ FMIS នៅតាមក្រសួង-ស្ថាប័នទាំង ១០ ដូចនេះ សូមអ្នកពាក់ព័ន្ធទាំងអស់ត្រៀមខ្លួនចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះឱ្យបានទៀតទាត់ទាំងអស់គ្នា ៕*

សម្រាប់ព័ត៌មានបន្ថែមផ្សេងៗ សូមចូលទៅកាន់គេហទំព័រ ឬទំនាក់ទំនងតាមអ៊ីមែល ឬទូរស័ព្ទដូចខាងក្រោម÷

*គេហទំព័រ÷ http://fmis.mef.gov.kh  អ៊ីមែល÷ fmis.info@mef.gov.kh  ទូរស័ព្ទទំនាក់ទំនង÷ 023 430 063*

**FMIS CAMBODIA**  **FMIS CAMBODIA**